ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គស្នងការដ្ឋាននគរបាលជាតិ
លេខៈ ០១១ សណ/ន

# សេចក្តីណែនាំ
## ស្តីពី
## ការប្រើប្រាស់ឯកសណ្ឋាន សញ្ញាស័ក្តិ និងឧបករណ៍សម្ភាររបស់ភ្នាក់ងារសន្តិសុខឯកជន

អនុវត្តតាមខ្លឹមសារអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងសន្តិសុខឯកជន ក្នុងគោលបំណងបញ្ចៀសការភាន់ច្រឡំនៃការប្រើប្រាស់ឯកសណ្ឋាន សញ្ញាស័ក្តិ និងឧបករណ៍សម្ភាររបស់ភ្នាក់ងារសន្តិសុខឯកជន ដែលដូច ឬស្រដៀងទៅនឹងនគរបាលចរាចរណ៍ កម្លាំងមានសមត្ថកិច្ច កម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងរបស់ក្រសួង ឬស្ថាប័នរដ្ឋនានា អគ្គស្នងការដ្ឋាននគរបាលជាតិ សូមធ្វើការណែនាំដល់បណ្តាក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន និងសហគ្រាសគ្រឹះស្ថាន ដែលជ្រើសរើសភ្នាក់ងារសន្តិសុខឯកជន ដូចខាងក្រោម៖

១-ត្រូវអនុវត្តតាមលក្ខន្តិកៈ នៃការស្នើសុំប្រកបអាជីវកម្មផ្តល់សេវាសន្តិសុខឯកជន របស់ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន ឬការជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនរបស់សហគ្រាសគ្រឹះស្ថាននានា មានលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំចំនួន ១៦ចំណុច ជាពិសេសគំរូឯកសណ្ឋានភ្នាក់ងារសន្តិសុខឯកជន មានស្លាកសញ្ញាក្រុមហ៊ុន និងគំរូឧបករណ៍សម្ភារបច្ចេកទេស មធ្យោបាយ សត្វ សម្រាប់បំពាក់ឱ្យភ្នាក់ងារសន្តិសុខឯកជន។

២-ហាមប្រើប្រាស់ឯកសណ្ឋាន សញ្ញាស័ក្តិ ឧបករណ៍សម្ភាររបស់ភ្នាក់ងារសន្តិសុខឯកជន ដែលដូច ឬស្រដៀងទៅនឹងនគរបាលចរាចរណ៍ កម្លាំងមានសមត្ថកិច្ច កម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងរបស់ក្រសួង ឬស្ថាប័នរដ្ឋនានា ដែលមានចែងក្នុងមាត្រា ១៦ នៃអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ស្តីពីការគ្រប់គ្រងសន្តិសុខឯកជន។

៣-ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន និងសហគ្រាសគ្រឹះស្ថាន ដែលមានឯកសណ្ឋានដូច ឬស្រដៀងទៅនឹងនគរបាលចរាចរណ៍ កម្លាំងមានសមត្ថកិច្ច ឬកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ត្រូវធ្វើការផ្លាស់ប្តូរ ហើយស្នើសុំតាមរយៈនាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន ចំពោះក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន និងតាមរយៈស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ចំពោះសហគ្រាសគ្រឹះស្ថាន។

៤-ករណីការប្រើប្រាស់ឯកសណ្ឋាន សញ្ញាស័ក្តិ និងឧបករណ៍សម្ភាររបស់ភ្នាក់ងារសន្តិសុខឯកជន ឬស្លាកសញ្ញាក្រុមហ៊ុន សហគ្រាសគ្រឹះស្ថាន ដោយគ្មានការអនុញ្ញាតត្រឹមត្រូវ ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន និងសហគ្រាសគ្រឹះស្ថានជ្រើសរើសភ្នាក់ងារសន្តិសុខឯកជន នឹងទទួលខុសត្រូវចំពោះមុខច្បាប់។

ទទួលបានសេចក្ដីណែនាំនេះ ប្រធាននាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន ស្នងការ នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត អគ្គនាយក អគ្គនាយិកាក្រុមហ៊ុនផ្ដល់សេវាសន្តិសុខឯកជន និងសហគ្រាសគ្រឹះស្ថាននានា ចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៧.១០ កើត ខែ ភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៧ ឆ្នាំ២០២៤

**អគ្គស្នងការនគរបាលជាតិ**

នាយឧត្តមសេនីយ៍.ស.ខេង

**ចម្លងជូន**

- ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ
- អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ
- ថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ
- សាលារាជធានី-ខេត្ត
  «ដើម្បីគោរពជូនជ្រាប-ជូនជ្រាប»
- ឯកសារ-កាលប្បវត្តិ